សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

លេខទី ០៤ ខែកក្កដា ឆ្នាំ២០១០



រូបថត: AP សត្វទុងជោគជាំដោយប្រេងដែលធ្លាយចេញនៅឈូងសមុទ្រ ម៉ិកស៊ិក

## ថ្ងៃបង្ហូរប្រេងត្រូវបានកំណត់

ដោយ វង្ស សុខេង

មន្ត្រីរដ្ឋាភិបាល បានឱ្យដឹងកាលពីថ្ងៃពុធថា ផលិតកម្មប្រេងដែលមានការទន្ទឹងរង់ចាំជាយូរមក ហើយនៅកម្ពុជា គ្រោងនឹងចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០១២ បន្ទាប់ពីការខួងអណ្តូងប្រេងនៅក្នុងសមុទ្របានផ្តល់លទ្ធផលវិជ្ជមាន។

ថ្លែងទៅកាន់និស្សិតមកពីសាកលវិទ្យាល័យពុទ្ធិសាស្ត្រ នៅសណ្ឋាគារ Raffles Le Royal ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមិថុនា លោក **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) បានមានប្រសាសន៍ថា លោកបានកំណត់កាលបរិច្ឆេទចាប់ផ្តើម ផលិតកម្មប្រេងរួចរាល់ហើយ។

លោកបានអះអាងថា "យើងសង្ឃឹមថា ប្រេងមួយដំណក់លើកដំបូង នឹងត្រូវផលិតនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០១២"។

លោក **ផៃ ស៊ីផាន** អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក៏បានអះអាងយ៉ាងដូច្នោះដែរ។

យោងតាមប្រភពក្រៅផ្លូវការ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ការអះអាងដូច្នេះបានធ្វើឡើងបន្ទាប់ពីមាន

តទៅទំព័រទី ២

## សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធានរៀបចំកិច្ចពិភាក្សាតុមូលជាមួយឯកឧត្តម ចូសេរ៉ាម៉ូសហ៊ តា (José Ramos-Horta)

ដោយ *John Forrest Millock* បុគ្គលិក ស៊ីអារអាធី

កាលពីថ្ងៃសុក្រទី២៣ ខែមេសា ឆ្នាំ២០១០ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន និងមូលនិធិសន្តិភាពអន្តរជាតិ រួមជាមួយ មូលនិធិ Heinrich Boll បានរៀបចំនូវកិច្ចពិភាក្សាតុមូលស្តីពី "ការបំលែងភោគទ្រព្យធនធានធម្មជាតិឱ្យទៅជាប្រភពសំរាប់សម្រាប់រីកចម្រើនប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍប្រជាធិបតេយ្យ"។

កិច្ចពិភាក្សាតុមូលនេះ មានការចូលរួមពីវាគ្មិនចំនួន២រូប គឺឯកឧត្តមបណ្ឌិត **ចូសេរ៉ាម៉ូសហ៊ តា** (Dr. José Ramos-Horta) ជ័យលាភីពានរង្វាន់ណូបែលសន្តិភាពនៅឆ្នាំ១៩៩៦ បច្ចុប្បន្នជាប្រធានាធិបតីនៃប្រទេសទីម័រឡេស្តេ និងឯកឧត្តមបណ្ឌិត **ផាន់ ផល្លា** អគ្គលេខាធិការងារនៃឧត្តមក្រុមប្រឹក្សា

តទៅទំព័រទី ២

## ទស្សនៈវិស័យ

ទស្សនៈវិស័យរបស់ CRRT គឺភោគទ្រព្យដែលបានមកពីឧស្សាហកម្មនិស្សារណកម្ម ត្រូវមានការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវផ្នែកសង្គម ដែលមានតម្លាភាព គណនេយ្យភាព និងការចូលរួម ដើម្បីធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ទទួលបានផលចំណេញប្រកបដោយសមធម៌។

## ឧបទ្ទវហេតុប្រេងធ្លាយនៅឈូងសមុទ្រជាការរំលឹកពីកង្វះខាតកម្ពុជា

ដោយ ពេជ្រ សំណាង, *VOA*

"សំរាប់ការរៀបចំឆ្លើយតប នៅពេលដែលមានការកំពប់ប្រេង រដ្ឋាភិបាលគួរតែពិចារណាឱ្យមានអាជ្ញាធរផ្សេង ហើយនឹងអាជ្ញាធរសុវត្ថិភាពប្រេងដែលអាជ្ញាធរហ្នឹងលោកអាចត្រួតពិនិត្យទៅលើសុវត្ថិភាព ហើយនិងសុខភាពជាពិសេសលើកទឹកចិត្តឱ្យក្រុមហ៊ុនប្រេងទាំងអស់ បង្កើតឱ្យមានសមាគមដើម្បីឆ្លើយតប នៅពេលណាដែលមានកំពប់ប្រេងនៅពេលអនាគត"។

ក្រុមអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការងារតាមដានដំណើរការរុករក និងធ្វើអាជីវកម្មប្រេងនៅក្នុងប្រទេសកម្ពុជា បានទទូចស្នើឱ្យរដ្ឋាភិបាលរៀបចំយន្តការ ឆ្លើយតបទៅនឹងហានិភ័យឬគ្រោះថ្នាក់ធ្លាយប្រេងជាយថាហេតុណាមួយ ឱ្យបានរួចរាល់ជាមុនសិន មុននឹងអនុញ្ញាតឱ្យក្រុមហ៊ុនដែលកំពុងរុករកប្រេងនៅក្នុងដែនសមុទ្រខ្មែរ ចាប់ផ្តើមដំណើរការបូមយកប្រេង ពីក្រោមបាតសមុទ្ររបស់កម្ពុជានោះ។

តទៅទំព័រទី ៣

## មាតិកា


- ថ្ងៃបង្ហូរប្រេងត្រូវ (ត) ............ ២
- សម្ព័ន្ធភាពកម្ពុជា (ត) ............ ២
- ឧបទ្ទវហេតុប្រេងធ្លាយ (ត) ............ ៣
- តម្លាភាពមានភាពកើនឡើង ............ ៤
- ប្រទេសអេក្វាតូរៀលហ្គីណេ ............ ៦
- សិក្ខាសាលារបស់ EITI ............ ៦

តមកពីទំព័រទី ១

## ថ្ងៃបន្ទរប្រេងត្រូវ...

កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់ CNPA ជាមួយក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ចំពោះការរុករកប្រេងនៅប្លុក A ក្នុងសមុទ្រដែលមានទំហំ **៤៧០៩ គីឡូម៉ែត្រការ៉េ** នៅឈូងសមុទ្រថៃ។

ក្រុមហ៊ុនដែលមានផលប្រយោជន៍នៅប្លុក A រួមមាន ក្រុមហ៊ុនផលិតថាមពលដ៏ធំ *Chevron* ដែលកំពុង ដំណើរការរុករកប្រេងរបស់ខ្លួននៅតំបន់សម្បទាន និងមានភាគហ៊ុន ៣០ភាគរយ បន្ទាប់មកទៀតគឺក្រុមហ៊ុន *Mitsu Oil Exploration Cooperation (MOECO)* ដែលមានភាគហ៊ុន ៣០ភាគរយ ក្រុមហ៊ុន Kris Energy មានភាគហ៊ុន ២៥ភាគរយ និង GS Caltex របស់កូរ៉េខាងត្បូង មានភាគហ៊ុន ១៥ភាគរយ។

កាលពីខែមេសា ឆ្នាំនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាអោយក្រុមហ៊ុន Chevron ចាប់ផ្តើមផលិតកម្មប្រេងនៅត្រឹមឆ្នាំ ២០១២ បើមិនដូច្នោះទេ ក្រុមហ៊ុននេះនឹងត្រូវប្រឈមនឹងការដកហូតអាជ្ញាប័ណ្ណរុករករ៉ែនៅតំបន់នោះ។

យោងតាមប្រភពដែលដឹងរឿងនេះ ដៃគូពាក់ព័ន្ធ ៤ មកពីក្រុមហ៊ុនខាងលើ បានចូលរួមក្នុងគណៈកម្មការពិនិត្យវាយតំលៃរួមជាមួយCNPA កាលពីថ្ងៃសុក្រ ដើម្បីបង្ហាញលទ្ធផលវិជ្ជមានទាក់ទងនឹងអណ្តូងខួងរុករកប្រេង ៣ កន្លែង នៅប្លុកនោះ។

ប្រភពដដែលនោះបានឱ្យដឹងថា បើតាមការរំពឹងទុក ក្រុមហ៊ុនទាំងនោះត្រូវបញ្ជូនរបាយការណ៍ចុងក្រោយ ស្តីពីផលិតកម្មប្រេងចុងក្រោយនៅថ្ងៃទី១៨ ខែកញ្ញា ខាងមុខនេះ ដែលជាកាលបរិច្ឆេទផ្លាស់ប្តូរអាជ្ញាប័ណ្ណរុករកប្រេងថ្មី។

ប្រភពនោះបានបន្ថែមទៀតថា ភាគទុនិកនៅប្លុកA បាន "បង្ហាញក្តីបារម្ភ" ចំពោះវិសមភាពរវាងច្បាប់ពន្ធដារ និងសេចក្តីព្រាងច្បាប់ប្រេងកាតដែលពួកគេរំពឹងថា ជាអាទិភាពមួយសម្រាប់សភាជាតិអនុម័ត។

លោក Gareth Johnstone អ្នកនាំពាក្យរបស់Chevron មិនអាចឆ្លើយតបនឹងសំណើតាមអ៊ីម៉ែល ដើម្បីឱ្យលោកបកស្រាយលម្អិត ទាក់ទងនឹងដំណើរការរីកចំរើនក្នុងការរុករកប្រេងនៅប្លុក A ទេ។ម្យ៉ាងវិញទៀតលោកក៏មិនបានបញ្ជាក់អះអាងអំពីកាលបរិច្ឆេទកំណត់ថ្ងៃផលិតប្រេងដែរ។

ថ្វីបើយ៉ាងនេះក្តីលោកបានអះអាងថា: "យើងឱ្យ Chevron អនុលោមទៅតាមសេចក្តីចង់បានរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផលិតប្រេងនៅប្លុក A ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន"។

លោកបានបន្ថែមថា: "កាលបរិច្ឆេទផលិតប្រេងលើកដំបូង អាស្រ័យលើកម្មវិធីរុករកប្រេងដោយជោគជ័យ និងការសម្រេចបាននូវចំណុចដៅសំខាន់ៗ"។

លោក តែ ដួងតារា ប្រធាន CNPA មិនអាចទាក់ទងសុំយោបល់បានឡើយកាលពីថ្ងៃពុធ។/

**រាយការណ៍បន្ថែមដោយ** Ellie Dyer **និង ស៊ីន សាយ**

**អត្ថបទមានការសុំសិទ្ធិឱ្យបោះពុម្ពឡើងវិញពី ភ្នំពេញប៉ុស្តិ៍**

តមកពីទំព័រទី ១

## សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាព...

សេដ្ឋកិច្ចជាតិកម្ពុជា(SNEC)។វាគ្មិនទាំងពីរ បានលើកយកនូវប្រធានបទមួយចំនួនមកបង្ហាញ រួមមានវិស័យឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា និងវិធីសាស្ត្រថ្នាក់ជាតិក្នុងការគ្រប់គ្រងធនធាន ឧទាហរណ៍នៃការអនុវត្តការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព (ផ្តោតលើករណីសិក្សានៅប្រទេសទីម័រឡេស្តេ) និងចំណុចសំខាន់ៗនៃតម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម។

ឯកឧត្តមប្រធានាធិបតី ចូសេរ៉ាម៉ូសហ៊័ត្តា (Dr. José Ramos-Horta) បានលើកឡើងពីការអភិវឌ្ឍធនធានធម្មជាតិនៅក្នុងប្រទេសរបស់គាត់ថា "ដោយមានជំនួយពីអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍនានា រដ្ឋាភិបាលរបស់យើងកំពុងផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋទូទាំងប្រទេស"។ ឯកឧត្តមក៏បានលើកឡើងនូវវិធានការណ៍ផ្សេងៗ ដែលរដ្ឋាភិបាលទីម័រឡេស្តេ បាននឹងកំពុងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព ការទប់ស្កាត់អំពើពុករលួយ និងផ្សារភ្ជាប់ជាមួយសហគមន៍ទាំងអស់ ដូចជា ការបង្កើតឱ្យមាននូវតុល្យភាពនៃអំណាច ដោយទុកដាក់ប្រាក់ចំណូលដែលបានមកពីប្រេង និងឧស្ម័ន តាមរយៈការរៀបចំគំរោងថវិកាជាតិ ដោយមិនអនុញ្ញាតិឱ្យរដ្ឋាភិបាលគ្រប់គ្រងដោយផ្ទាល់ទៅលើប្រាក់ចំណូលទាំងនោះទេ។ ជាសមាជិកមួយរបស់គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ប្រទេសទីម័រឡេស្តេបានអនុម័តនូវច្បាប់ប្រេងកាត ដើម្បីត្រួតពិនិត្យការគ្រប់គ្រងទៅលើធនធានប្រេង និងឧស្ម័ន របស់ខ្លួន និងបានបង្កើតមូលនិធិប្រេងកាត និងនាយកដ្ឋានគ្រប់គ្រងមូលនិធិប្រេងកាត ដែលទទួលខុសត្រូវទៅលើការវិនិយោគនូវចំណូលប្រេងកាតនេះ និងការទទួលខុសត្រូវចំពោះធនាគារកណ្តាល។ ម្យ៉ាងវិញទៀត នៅពេលដែលប្រទេសចង់បង្កើតនូវយុទ្ធសាស្ត្រ និងផែនការសំរាប់ជាតិ ការពិគ្រោះយោបល់ជាសាធារណៈគឺត្រូវតែមាន។

ឯកឧត្តមបណ្ឌិត ចូសេរ៉ាម៉ូសហ៊័ត្តា បានបញ្ជាក់ថា "ខ្ញុំឱ្យអ្នកប្រសើរជាង លោក បែរណាត ម៉ាដូវ (Bernard Madoff) បានសន្យា។ លោក បែរណាតម៉ាដូវ (Bernard Madoff) (ម្ចាស់ធនាគារនៅទីក្រុងញ៉ូវយ៉ក និងបច្ចុប្បន្ននៅក្នុងពន្ធនាគារនៅឡើយ) ជាអ្នកដែលបានសន្យាឱ្យមកវិញនូវប្រាក់ចំណេញ ៨% ឬ ១០%។ ខ្ញុំឱ្យអ្នកឯងវិញចំណេញ ១០០% ប្រសិនបើយើងធ្វើការវិនិយោគឱ្យបានច្រើនលើវិស័យអប់រំចាប់ពីថ្នាក់បឋមរហូតដល់មហាវិទ្យាល័យ។ ប្រសិនបើយើងវិនិយោគលើវិស័យសុខាភិបាល កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ខ្ញុំសូមធានាថា ២០ឆ្នាំក្រោយ អ្នកនឹងទទួលបាននូវទឹកប្រាក់ចំណេញត្រលប់វិញ ១០០%"។ នៅពេលពិភាក្សាពីបញ្ហាអំពើពុករលួយរបស់រដ្ឋាភិបាល ឯកឧត្តមប្រធានាធិបតី ក៏បានទទួលស្គាល់ថា អំពើពុករលួយនៅតែជាឧបសគ្គ ក៏ប៉ុន្តែឯកឧត្តមបានសង្កត់ធ្ងន់ថា រដ្ឋមន្ត្រី អគ្គនាយករបស់ក្រសួង និងនាយកដ្ឋានទាំងឡាយ ដែលមានពាក់ព័ន្ធនឹងអំពើពុករលួយ ត្រូវតែទទួលខុសត្រូវបញ្ឈប់ជាបន្ទាន់។

ចំណែក ឯកឧត្តមបណ្ឌិត ផាន់ ផល្លា បានធ្វើការប្រៀបធៀបបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់កម្ពុជា ជាមួយប្រទេសទីម័រឡេស្តេ ដោយគូសបញ្ជាក់ពីភាពក្មេងខ្ចីរបស់ឧស្សាហកម្មរ៉ែ ប្រេង និងឧស្ម័ន ក៏ដូចជា រចនាសម្ព័ន្ធគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តមបណ្ឌិត បានគូសបញ្ជាក់ផងដែរថា អ្វីដែលគាត់ដឹងគឺថា បញ្ហាចំបងដែលកម្ពុជាត្រូវពុះពារដើម្បីធ្វើឱ្យឧស្សាហកម្ម រ៉ែ ប្រេង និងឧស្ម័ន មានការរីកចំរើន គឺកង្វះសមត្ថភាព ពោលគឺខ្វះខាតវិស្វករជំនាញ និងហេដ្ឋារចនាសម្ព័ន្ធសង្គម។

តមកពីទំព័រទី ១

## ឧបទ្ទវហេតុប្រេងធ្លាយ...

ការលើកឡើងនេះបានធ្វើឡើងបន្ទាប់ពីមានឧបទ្ទវហេតុធ្លាយប្រេងដ៏ធំសម្បើមមួយ របស់ក្រុមហ៊ុនប្រេង BP នៅក្នុងឈូងសមុទ្រម៉ិកស៊ិកកាលពីខែមេសាកន្លងទៅនេះ។ ការធ្លាយប្រេងដែលអូសបន្លាយពេលអស់ជាង៦សប្តាហ៍មក-ហើយនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន ដោយសារតែប្រេងចំនួនជាង ១ម៉ឺនធុងបារ៉ែលក្នុងមួយថ្ងៃ ត្រូវគេប៉ាន់ប្រមាណថា បានហៀរចេញពីអណ្តូងប្រេងដែលធ្លាយនោះ។ ការ-ហៀរប្រេងពាសពេញសមុទ្រនេះ បានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ពលរដ្ឋអាមេរិកនៅតាមបណ្តោយឆ្នេរសមុទ្រនោះ ជាពិសេសនៅតាមបណ្តោយឆ្នេរសមុទ្ររដ្ឋ Louisiana តែម្តងដែលពួកគេភាគច្រើន ពឹងផ្អែកទៅលើរបរនេសាទក្នុងសមុទ្រនោះ។

លោក ម៉ម សម្បត្តិ ប្រធានក្រុមប្រឹក្សា-ភិបាលនៃអង្គការសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ដែលបានតាមឃ្លាំមើលជាប្រចាំនូវដំណើរការវិនិយោគលើវិស័យឧស្សាហកម្ម-និស្សារណកម្ម ឬការធ្វើអាជីវកម្មខាងឧស្ម័ន រ៉ែ និងប្រេងកាតនៅក្នុងប្រទេសកម្ពុជានេះ មានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាគួរតែបង្កើតស្ថាប័នទទួលខុសត្រូវលើការឆ្លើយតបទៅនឹងឧបទ្ទវហេតុធ្លាយប្រេងណាមួយ ខណៈដែលប្រទេសដ៏ក្រីក្រមួយនេះពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់ខាងឧស្សាហកម្មប្រេងនៅឡើយ ហើយដែលកំពុងត្រៀមខ្លួនទទួលផលពីការធ្វើអាជីវកម្មប្រេង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀតនេះ។

"សម្រាប់ការរៀបចំឆ្លើយតប នៅពេលដែលមានការកំពប់ប្រេង រដ្ឋាភិបាលគួរតែពិចារណាឱ្យមានអាជ្ញាធរឆ្នេរ និងអាជ្ញាធរសុវត្ថិភាពប្រេង ដែលអាជ្ញាធរហ្នឹង លោកអាចត្រួតពិនិត្យទៅលើ-សុវត្ថិភាព និងសុខភាព ជាពិសេសលើកទឹកចិត្តឱ្យក្រុមហ៊ុនប្រេងទាំងអស់ហ្នឹង បង្កើតឱ្យមានសមាគម ដើម្បីឆ្លើយតបនៅពេលណាមានកំពប់ប្រេងនៅពេលអនាគត"។

សូមបញ្ជាក់ថា អង្គការ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន គឺជាបណ្តុំអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ចំនួន ៥ ដែលរួបរួមគ្នាដើម្បីតាមដានមើលដំណើរការធ្វើអាជីវកម្មលើវិស័យប្រេងរ៉ែនិងឧស្ម័ននិងការគ្រប់គ្រងចំណូលដែលបានមកពីការធ្វើអាជីវកម្មលើវិស័យទាំងនេះ។







*រូបថត: BP, ប្រទេសដែលមានការកើនឡើងផលិតផលប្រេង និងប្រទេសដែលផលិតហ្គាស ច្រើនជាងគេក្នុងឆ្នាំ ២០០៩*

លោក ម៉ម សម្បត្តិ មានប្រសាសន៍បន្ថែមថា អាជ្ញាធរដែលទទួលបន្ទុកឆ្លើយតបទៅនឹងគ្រោះ-ថ្នាក់ប្រេងជាយថាហេតុនេះ ចាំបាច់ត្រូវតែបង្កើត-ឡើងដាច់ដោយឡែកពីអាជ្ញាធរប្រេងកាតជាតិកម្ពុជាដែលមានស្រាប់ ដើម្បីធានាខាងផ្នែកបច្ចេកទេសក្នុងការគ្រប់គ្រងការធ្លាយប្រេង ឬឧបទ្ទវហេតុគ្រោះថ្នាក់ប្រេងដទៃទៀត ប្រកបដោយប្រសិទ្ធិភាព។

បច្ចុប្បន្នមានក្រុមហ៊ុនចំនួន១៣បានទទួលសិទ្ធិរុករកប្រេងនៅកម្ពុជាដោយក្រុមហ៊ុនខ្លះបានចាប់-ផ្តើម និងកំពុងដំណើរការរុករករបស់ខ្លួនរួចស្រេចទៅហើយ។

គេរំពឹងថាក្រុមហ៊ុនមួយចំនួនដោយរួមទាំងក្រុមហ៊ុនរបស់អាមេរិក ដែលបានទទួលសិទ្ធិរុករកប្រេងនៅក្នុងប្លុកA ក្នុងដែនសមុទ្រកម្ពុជាផងដែរ-នោះ នឹងចាប់ផ្តើមធ្វើអាជីវកម្មបូមយកប្រេងនៅត្រឹមឆ្នាំ២០១២ ឬ ២០១៣ ខាងមុខនេះ។

ការធ្វើអាជីវកម្មប្រេងនេះ ត្រូវគេប៉ាន់ប្រមាណថានឹងអាចផលិតប្រេងបានចំនួនពី ៤០០ ទៅ ៧០០ លានធុងបារ៉ែល ដែលនឹងអាចធ្វើឱ្យកម្ពុជាទទួលបានប្រាក់ចំណូលចំនួនពី៥០០លានទៅ១ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ ពីផលិតកម្មឧស្ម័ន និងប្រេងនេះ។ នេះបើយោងតាមរបាយការណ៍ឆ្នាំ២០០៦ របស់ធនាគារអភិវឌ្ឍន៍អាស៊ី។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស-កម្ពុជា ដែលបានតាមដានយ៉ាងជាប់លាប់នូវនិន្នា-ការវិវត្តន៍ខាងវិស័យប្រេង រ៉ែ និងឧស្ម័នផងដែរនេះ មានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាគួរតែរៀបចំឱ្យមានកិច្ចព្រមព្រៀងជាក់លាក់ជាមួយក្រុមហ៊ុនរុករកប្រេងទាំងអស់ ដោយតម្រូវឱ្យក្រុមហ៊ុនរុក-រកប្រេងទាំងនោះ មានវិធានការគ្រប់គ្រាន់ ដើម្បីបង្ការ និងឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពចំពោះគ្រោះថ្នាក់លិច ឬ ធ្លាយប្រេង ជាយថាហេតុណាមួយ។

"កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនណាមួយក៏ដោយ ក៏ត្រូវដាក់បន្ទុកហ្នឹងឱ្យក្រុមហ៊ុន ក្នុងការ-រៀបគម្រោង បង្ការរបស់ខ្លួន ហើយបើគម្រោងបង្ការហ្នឹងមើលទៅវាមិនសមហេតុ ឬ មិនគ្រប់គ្រាន់អាហ្នឹងរដ្ឋាភិបាលអាចបដិសេធ នូវគម្រោងមួយណាក៏បានដែរ។ អញ្ចឹង រដ្ឋាភិបាលអាចធ្វើយ៉ាងម៉េចឱ្យក្រុមហ៊ុនមានគម្រោងលំអិតបង្ហាញចំពោះខ្លួន និងប្រជាពលរដ្ឋរបស់ខ្លួននូវគម្រោងការពារគ្រប់រូបភាពទាំងអស់"។

លោក អ៊ូ វីរៈ មានប្រសាសន៍បន្ថែមថា រដ្ឋាភិបាលកម្ពុជា ក៏គួរតែដាក់ពាក្យស្នើសុំចូលជាសមាជិកនៃអង្គការ "តម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម" (Extractive Industry Trans-parency Initiative) ផងដែរ ដើម្បីសិក្សាពីវិធី-

តទៅទំព័រទី ៥

# តម្លាភាពមានការកើនឡើង ប៉ុន្តែវាស្ថិតលើកំណាត់ផ្លូវឆ្ងាយ




ដោយ Steve Finch, ភ្នំពេញប៉ុស្តិ៍

ក្នុងអំឡុងបទបង្ហាញធម្មតាមួយ ស្តីពីសេដ្ឋកិច្ចកម្ពុជា កាលពីថ្ងៃទី១៧ ខែមីនា ឯកឧត្តម ហង់ ជួនណារ៉ុន អគ្គនាយកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសំរេចចិត្តយកស្លាយចុងក្រោយមកបង្ហាញអំពីសេចក្តីសង្ខេបដ៏កម្រ និងលំអិតអំពីកំណើនប្រាក់ចំណូលបានពីប្រេង និងឧស្ម័ននៅកម្ពុជា។

ការសំរេចចិត្តនេះបានឆ្លុះបញ្ចាំងពីចំណុចដៅដ៏សំខាន់នៅក្នុងតម្លាភាពនៅកម្ពុជាក៏ដូចជាចំណុចដៅដ៏សំខាន់ សម្រាប់រដ្ឋាភិបាលដែរ។

ម្យ៉ាងវិញទៀត ការលាតត្រដាងរបស់ឯកឧត្តម ហង់ ជួនណារ៉ុន ដែលថារដ្ឋាភិបាល បានទទួលទឹកប្រាក់ ៨០ម៉ឺនដុល្លារ កាលពីខែធ្នូ និង ២៦លានដុល្លារកាលពីខែមករា គឺជា "ប្រាក់បន្ថែមសម្រាប់ការចុះហត្ថលេខា" លើកិច្ចព្រមព្រៀងរុករកថាមពល និង "មូលនិធិសង្គម" បានឆ្លុះបញ្ចាំងឱ្យឃើញពីកម្រិតថ្មីនៃតម្លាភាពចំណាយក្នុងឧស្សាហកម្មរុករកប្រេងនៅកម្ពុជា។

ទោះជាយ៉ាងណា រដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រឈមនឹងការលំបាកចេះតែកើនឡើងក្នុងការឆ្លើយសំណួរ ថាតើប្រាក់ទាំងនោះបានមកពីណា តើប្រាក់ទាំងនោះយកទៅចំណាយដោយរបៀបណា តើប្រាក់ដែលទទួលបានពីឧស្សាហកម្មរុករកប្រេង នឹងត្រូវបើកចំហឱ្យមានការពិនិត្យតាមដានជាសាធារណៈកម្រិតណា។

ការបាត់បង់ទឹកប្រាក់ចំនួន ៥០ម៉ឺនដុល្លារអាមេរិក ដែលតាមរបាយការណ៏ក្រុមហ៊ុនរុករករ៉ែដែកធំបំផុតលើពិភពលោក គឺក្រុមហ៊ុន BHP Billiton បានផ្តល់ដល់រដ្ឋាភិបាល បានក្លាយជាប្រធានបទក្នុងការស៊ើបអង្កេតមួយរបស់គណៈកម្មការមូលប័ត្រអាមេរិក។ ទឹកប្រាក់ដែលបានបាត់បង់នេះហាក់ដូចជាចំនុចចាប់ផ្តើមមួយ ដែលនាំឱ្យមានការចោទសួរទៅកាន់រដ្ឋាភិបាលកាន់តែច្រើនឡើងៗ ទាក់ទងនឹងចម្ងល់ដែលថា តើលុយនេះបានបាត់ទៅណា?

ជាលើកដំបូងរដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយជាសាធារណៈនូវចំណូលរដ្ឋ រាប់បញ្ចូលទាំងទឹកប្រាក់ដែលក្រុមហ៊ុនរុករករ៉ែ និងថាមពលរបស់បរទេសបានផ្តល់ដល់រដ្ឋាភិបាលដើម្បីធ្វើអាជីវកម្មរុករករ៉ែនៅកម្ពុជាផងដែរ។ TOFE (សេចក្តីប្រកាសអំពីប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ) ដែលមួយផ្នែកត្រូវបានបង្ហាញក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានបង្ហាញទាំងស្រុងនៅក្នុងសន្និសីទស្តីពី ឧស្សាហកម្មរុករករ៉ែ ដែលរៀបចំឡើងដោយអង្គការ Oxfam America កាលពីចុងខែមីនា នៅរាជធានីភ្នំពេញ បានបង្ហាញថា រដ្ឋបានទទួលទឹកប្រាក់ប្រហែលជា ៩,៣២៣ ពាន់លានរៀល (២,២៥ លានដុល្លារ) ពីវិស័យរុករករ៉ែកាលពីឆ្នាំ២០០៩។ ក្នុងនោះទឹកប្រាក់ ៦,០០៣ ពាន់លានរៀល (១,៤៥ លានដុល្លារ) ទទួលបានពីក្រុមហ៊ុនរុករករ៉ែហើយនៅសល់ ៨០ ម៉ឺនដុល្លារទៀត ទទួលបានពីវិស័យរុករករ៉ែ។ នេះបើយោងទៅតាមតួលេខជាផ្លូវការណ៏របស់រដ្ឋាភិបាល។

ប៉ុន្តែដោយមានក្រុមហ៊ុនរុករករ៉ែ OZ របស់អូស្ត្រាលី និងក្រុមហ៊ុន Southern Gold កំពុងសម្លឹងមើលការផលិតរ៉ែមាសនៅកម្ពុជា ស្របពេលដែលក្រុមហ៊ុនរុករកថាមពល Chevron របស់សហរដ្ឋអាមេរិក ស្ថិតក្រោមសម្ពាធរបស់រដ្ឋាភិបាលកម្ពុជាឱ្យចាប់ផ្តើមរុករកប្រេងឱ្យបានឆាប់រហ័សនៅត្រឹមឆ្នាំ២០១២នោះ គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ក្នុងចំណោមស្ថាប័នផ្សេងៗទៀត កំពុងជំរុញឱ្យរដ្ឋាភិបាលបង្ហាញថែមទៀត នូវអ្វីដែលពួកគេគិតថានៅតែមិនទាន់បានបង្ហាញឱ្យបានលម្អិត។

លោក ម៉ម សម្បត្តិ នាយកប្រតិបត្តិរបស់អង្គការ ឪភីអេ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) បានលើកឡើងថា "ខ្ញុំគិតថានេះជាជំហានដំបូង ដែលរដ្ឋាភិបាលធ្វើ ដើម្បីបង្ហាញព័ត៌មាននេះដល់សាធារណជន"។

លោកបានបន្ថែមថា "ប៉ុន្តែគេគួរលើកកម្ពស់របៀបក្នុងការលាតត្រដាងព័ត៌មាន ដោយការផ្តល់ព័ត៌មានកាន់តែលម្អិតជាងនេះ"។

## ការស្វែងរកការផ្សព្វផ្សាយព័ត៏មានពេញលេញ

EITI គឺតម្រូវឱ្យមានការបើកទូលាយលើការផ្សព្វផ្សាយព័ត៌មានក៏រិតខ្ពស់ និងក្នុងតំណាក់កាលជាច្រើន ដែលចាប់ផ្តើមជាមួយការតាំងចិត្តរបស់រដ្ឋាភិបាល និងបញ្ចប់ទៅជាមួយនឹងដំណើរការដ៏មានសុពលភាព។ EITI បច្ចុប្បន្នមានសមាជិកចំនួន ២៩ ប្រទេស។ ដើម្បីចូលជាសមាជិករបស់ EITI រាជរដ្ឋាភិបាលត្រូវតែមានឆន្ទៈក្នុងការសហការការងារជាមួយបណ្តាអ្នកពាក់ព័ន្ធ ដែលរួមមានវិស័យឯកជន និងសង្គមស៊ីវិល មុនពេលដែលធ្វើការតែងតាំងប្រធានក្រុមអនុវត្តន៏ការងារ មុនពេលធ្វើការបោះពុម្ពផែនការការងារផ្សេងៗ។ នៅពេលដែលក្លាយជាបេក្ខជន EITI ជំហានដំបូង គឺត្រូវតែបង្កើតក្រុមការងារពហុពាក់ព័ន្ធមួយ។ ខណៈនេះកម្ពុជាត្រូវតែបង្ហាញពីឆន្ទៈមួយចំនួន បើទោះបីជាអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុញ្ញាតធ្វើការតែជាអ្នកឃ្លាំមើលក្នុងកិច្ចពិភាក្សាទៅលើការកែទម្រង់ហិរញ្ញវត្ថុក៏ដោយ។ ជាពិសេស រដ្ឋាភិបាលដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្អាក់ការស្នើសុំរបស់សង្គមស៊ីវិល ដើម្បីក្លាយជាដៃគូពេញលេញមួយ នៃដំណើរការកែទម្រង់ហិរញ្ញវត្ថុ ដែលបានចាប់ផ្តើមតាំងពីការចាប់ផ្តើមឆ្នាំ ២០០៩។ នៅពេលដែលរដ្ឋាភិបាលឈានដល់ដំណាក់កាលនៃដំណើរការ EITI រដ្ឋាភិបាលនឹងអនុញ្ញាតឱ្យចូលរួមយ៉ាងពេញលេញ។ តំណាក់កាលដែលសំខាន់បំផុតនោះ គឺការផ្សារភ្ជាប់ជាមួយក្រុមហ៊ុន ដែលជាអ្វីដែលរដ្ឋាភិបាល បានបង្ហាញនូវការអត់ឱនកន្លងមក ដោយឱ្យក្រុមហ៊ុន Chevron ជួយក្នុងបង្កើតច្បាប់ប្រេង។

គោលការណ៏ EITI នៅក្នុងតំណាក់កាលរៀបចំគេតម្រូវឱ្យរដ្ឋាភិបាលយល់ព្រមធ្វើការរាយការណ៏គំរូ និងមានរដ្ឋបាល EITI ឯករាជ្យមួយ ដែលធានាថាគណនេយ្យរបស់រដ្ឋ និងក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យយ៉ាងច្បាស់លាស់។

ជំហានបន្ទាប់ គឺការបើកចំហព័ត៌មាន ដែលបន្តមកតម្រូវឱ្យមានការបើកទូលាយរបស់រដ្ឋបាលនូវរាល់ចំណាយរបស់ក្រុមហ៊ុនឯកជន នៃផ្នែកមួយនៃដំណើរការ ដែលគណនេយ្យទាំងពីរនេះ នឹងត្រូវបានធ្វើការផ្ទៀងផ្ទាត់ពីភាពខុសគ្នា។ នេះគឺជាចំនុចសំខាន់ដែលកម្ពុជាបច្ចុប្បន្ននេះ កំពុងធ្វើការលើតម្រូវការស្តង់ដា ដែលទាំងរដ្ឋ និងក្រុមហ៊ុនឯកជន

តនៅទំព័របន្ទាប់

តមកពីទំព័រទី ៦

## ប្រទេសអេក្វាតូរៀលហ្គីណេ(Equatorial Guinea)...

"ប្រអប់ទទេស្អាតដែលទទួលរងបណ្តាសាពីធនធាន" ខណៈពេលដែលរបាយការណ៍ដទៃទៀត បានដាក់ចំណងជើង ពីបច្ចុប្បន្នភាពរបស់ប្រទេសអេក្វាតូរៀលហ្គីណេ ថា "ជាឧទាហរណ៍នៃប្រទេស ដែលទទួលរងទុក្ខទោសបណ្តាសាពីប្រេងក្នុងចំណោមបណ្តាប្រទេសដទៃដែលមានប្រេងដូចគ្នាដែរ "។

ក្នុងបរិបទនៃអំពើពុករលួយ និងការគ្រប់គ្រងមិនបានល្អ សេចក្តីសង្ឃឹមមិនប្រាកដប្រជា បានលេចឡើងនៅក្នុងទំរង់របស់គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ដែលជាប្រព័ន្ធគោលការណ៍ស្ម័គ្រចិត្ត ហើយក្នុងនោះប្រទេសអេក្វាតូរៀលហ្គីណេ បានយល់ព្រមចុះឈ្មោះនៅក្នុងឆ្នាំ ២០០៧។ ដើម្បីឱ្យក្លាយជាប្រទេសអនុវត្តតាមលក្ខន្តិកៈរបស់EITI ឱ្យបានពេញលេញគឺតំរូវឱ្យរដ្ឋាភិបាលប្រទេសអេក្វាតូរៀលហ្គីណេ ធានានូវការគ្រប់គ្រងចំណូលពីធនធានឱ្យមានតម្លាភាព ជាកាតព្វកិច្ចដោយមិនត្រឹមតែបង្ហាញតួលេខនៅក្នុងកិច្ចសន្យានិងតួលេខនៃការបង់ប្រាក់តែប៉ុណ្ណោះទេ តែក៏ត្រូវអនុញ្ញាតិឱ្យសង្គមស៊ីវិល ចូលរួមរាល់ដំណើរការដោយសេរី និងបើកចំហ នៅពេលដោះស្រាយបញ្ហាសំខាន់ៗ។

ជាការគួរឱ្យស្តាយដែលសេចក្តីសង្ឃឹមមិនប្រាកដប្រជានោះ បានរលាយបាត់ក្នុងខែមេសានេះ នៅពេលដែលសមាជិកក្រុមប្រឹក្សាភិបាលបានជួបប្រជុំ និងបោះឆ្នោតបដិសេធការស្នើសុំពន្យារពេលរបស់ប្រទេសនេះ ដោយបានបញ្ចប់នូវបេក្ខភាពជាសមាជិក។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាល បញ្ជាក់ពីលទ្ធភាពដាក់ពាក្យឡើងវិញ "ឧបសគ្គនៃការអនុវត្តឱ្យមានប្រសិទ្ធិភាព ត្រូវតែដោះស្រាយ"។ ក្រុមប្រឹក្សានេះក៏បានបញ្ជាក់ផងដែរថា "ប្រទេសណាដែលអនុវត្តមិនបានល្អឆ្លើយតបទៅនឹងលក្ខខណ្ឌតំរូវទេ មិនអាចក្លាយជាបេក្ខជនរបស់ EITI បានទេ"។ ក្រុមអ្នកឃ្លាំមើល បានយល់ស្របថា ប្រទេសអេក្វាតូរៀលហ្គីណេបានបង្ហាញនូវសញ្ញាតិចតួចក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលការណ៍តម្លាភាពលើការគ្រប់គ្រងប្រេង ចំណែកអ្នកខ្លះទៀតមានការភ្ញាក់ផ្អើល ចំពោះការសំរេចរបស់ EITI។

អវត្តមាននូវក្របខណ្ឌច្បាប់ ដែលតំរូវឱ្យមានតម្លាភាព និងបើកចំហ វាមិនទំនងដែលថាប្រទេសអេក្វាតូរៀលហ្គីណេ នឹងសំរបខ្លួនទៅតាមគោលការណ៍ច្បាប់នោះទេ។ ដោយបន្តដើរលើផ្លូវ បច្ចុប្បន្នការសន្យាអំពីអនាគតភ្លឺចិញ្ចាចចិញ្ចែង ដែលបានមកពីប្រាក់ដ៏សម្បើមនេះ ជាការខ្ជះខ្ជាយដោយឥតប្រយោជន៏ ហើយប្រទេសនេះនឹងទទួលរងការស្តីបន្ទោសជាច្រើន ដែលមិនធ្លាប់មានដើម្បីគេចផុតពីបណ្តាសាធនធាន។/

តមកពីទំព័រទី ៣

## ឧបទ្ទវហេតុប្រេងធ្លាយ...

សាស្ត្រ និងបទពិសោធន៏នានា ពីប្រទេសផ្សេងទៀត ក្នុងការគ្រប់គ្រងហានិភ័យ និងចំណូលបានពីការធ្វើអាជីវកម្ម ប្រេងនេះជាដើម។

អង្គការ EITI គឺជាអង្គការអន្តរជាតិមួយមានមូលដ្ឋាននៅក្នុងទីក្រុង Oslo ប្រទេសណ័រវ៉េស្សន៏ ដែលធ្វើការងារបង្កើនតម្លាភាពនៃចំណូល និងចំណាយរបស់រដ្ឋាភិបាល និងក្រុមហ៊ុនធ្វើអាជីវកម្មប្រេងនៅក្នុងប្រទេសជាង ៣០ នៅទូទាំងពិភពលោក។

ឯកឧត្តម ខៀវ កាញារិទ្ធ រដ្ឋមន្ត្រីក្រសួងព័តិមាន និងជាអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា មានប្រសាសន៏ថា ការចូលជាសមាជិករបស់អង្គការ EITI ឬក៏ការបង្កើតស្ថាប័នបន្ថែម ដើម្បីឆ្លើយតបទៅនឹងឧបទ្ទវហេតុធ្លាយប្រេងណាមួយនោះ គឺពុំចាំបាច់ទេ ដោយលោកបញ្ជាក់ថា រដ្ឋាភិបាលមានស្ថាប័ន និងក្រសួងពាក់ព័ន្ធ ដែលមានអ្នកជំនាញធំៗ ជាពិសេស គឺមានអាជ្ញាធរប្រេងកាតជាតិកម្ពុជារួចស្រេចហើយ។

"បង្កើតថែមទៀតនាំតែគេថាបង្កើនចំណាយលុយថែមទៀត ហើយក្រសួងនីមួយៗទទួលការខុសត្រូវរៀងខ្លួនបានហើយតើ"។

មន្ត្រីនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា បដិសេធមិនធ្វើអត្ថាធិប្បាយអំពីយន្តការឆ្លើយតបចំពោះហានិភ័យ ដែលអាចបណ្តាលមកពីការធ្លាយប្រេងជាយថាហេតុណាមួយ នៅពេលមានការធ្វើអាជីវកម្មប្រេងនៅកម្ពុជានេះទេ។

តែទោះជាយ៉ាងនេះក្តី ឯកឧត្តម ជាម យៀប សមាជិកសភាពីគណបក្សកាន់អំណាចមានប្រសាសន៏ថា ដោយមើលឃើញហេតុការណ៏ធ្លាយប្រេងដែលសហរដ្ឋអាមេរិកកំពុងជួបប្រទះនេះ រដ្ឋសភាជាតិកម្ពុជានឹងជំរុញឱ្យមានកិច្ចសន្យាដោយឡែកមួយ ជាមួយក្រុមហ៊ុនដែលកំពុងរុករកប្រេងនៅកម្ពុជា ដើម្បីធានាថា វិធានការឆ្លើយតបចំពោះឧបទ្ទវហេតុធ្លាយប្រេងណាមួយ ត្រូវមានរួចជាស្រេច មុននឹងក្រុមហ៊ុនទាំងនោះ អាចចាប់ផ្តើមធ្វើអាជីវកម្មបូមប្រេងនៅកម្ពុជាបាន។

"យើងយកកត្តាហ្នឹង ឬក៏យកបញ្ហាហ្នឹងធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ពិភាក្សាគ្នាហើយសម្រាប់កិច្ចសន្យាដោយឡែកមួយជាមួយក្រុមហ៊ុន ដែលត្រូវយកប្រេងដំបូងបំផុតនៅកម្ពុជាយើង គឺថាកុំឱ្យមានឧទាហរណ៏អាក្រក់ដូចជានៅឈូងសមុទ្រម៉ិកស៊ិកនោះ"។

ឯកឧត្តម យឹម សុវណ្ណ សមាជិកសភាមកពីគណបក្សប្រឆាំង សម រង្ស៊ី មានប្រសាសន៏ថា រដ្ឋសភាកម្ពុជា ក៏គួរតែបង្កើតច្បាប់គ្រប់គ្រងសុវត្ថិភាពនៃការធ្វើអាជីវកម្មប្រេងបន្ថែមទៀត ហើយរដ្ឋសភា ក៏ត្រូវជំរុញរដ្ឋាភិបាលឱ្យចូលជាសមាជិករបស់អង្គការ EITI ផងដែរ ដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាពនៃចំណូលដែលបានមកពីប្រេងនៅកម្ពុជានេះ។/

**អត្ថបទមានការសុំសិទ្ធិឱ្យបោះពុម្ពឡើងវិញពី VOA**

## តម្លាភាពមានការកើនឡើង...

មិនបានបើកទូលាយនូវរាល់ការចំណាយ ជាមួយនឹងការចងក្រង និងពិភាក្សាលើកិច្ចសន្យា ដែលមិនបញ្ចេញនូវរាល់ទិន្នន័យពាក់ព័ន្ធទាំងឡាយ។ នៅពេលដែលប្រទេសមួយបំពេញនូវរបាយការណ៏នេះហើយ គេនឹងតម្រូវឱ្យធ្វើការផ្សព្វផ្សាយ។ការត្រួតពិនិត្យក្រុមហ៊ុនលើការគាំទ្រការប្រតិបត្តិ នឹងត្រូវបានគេត្រួតពិនិត្យឡើងវិញ។ ហើយបន្ទាប់ពីធ្វើការវាយតំលៃខាងក្រោមក ប្រទេសមួយនេះ នឹងក្លាយជាប្រទេសប្រតិបត្តិ EITI។

**ប្រទេសប្រតិបត្តិ EITI**

អាហ្សែបៃហ្សង់ និង លីបីរៀ

**ប្រទេសជាបេក្ខជនរបស់ EITI**

អាហ្គានីស្ថាន អាល់បានៀ បួកគីណា ហ្វាសូ កាម៉ារូន សាធារណរដ្ឋអាហ្វ្រិកកណ្តាល ឆាត ឌីអាកង់ហ្គូ សាធារណរដ្ឋកង់ហ្គូ ឆ្នេរអាយវ៉រី កាប៊ុន កាញ៉ា ហ្គីណេ អ៊ីរ៉ាក់ កាហ្សាស្ថាន ម៉ាលី ម៉ូរីតានៀ ម៉ាដាកាស្ការ ម៉ុងហ្គូលៀ ម៉ូហ្សាមបិគ នីជឺ ណាយជីរៀ ណកវ៉េ ពេរ៉ូ សៀរ៉ា លីអន ទីម័រឡេស្តេ យ៉េមិន និងហ្សាមបៀ។/

**អត្ថបទមានការសុំសិទ្ធិឱ្យបោះពុម្ពឡើងវិញពី ភ្នំពេញប៉ុស្តិ៍**

## សិក្ខាសាលារបស់គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) នៅហ្សាកាតា

ដោយ ឃីម ហ្វីលី បុគ្គលិក ស៊ីអាអាធី

សមាជិកស្ថាបនិករបស់សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ហៅកាត់ CRRT ត្រូវបានអញ្ជើញដោយ គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ធនាគារពិភពលោក (World Bank) ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ និងអ៊ីនវ៉ែន (InWent) ដើម្បីចូលរួមក្នុងសិក្ខាសាលាស្តីពី ឱកាសពិសេស និងបញ្ហាប្រឈមនៃការអនុវត្តគោលការណ៍របស់ EITI នៅក្នុងតំបន់អាស៊ីដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១-៤ ខែមីនា ឆ្នាំ២០១០ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

លោក ឈិត សំអាត អនុប្រធានក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន និងជានាយកប្រតិបត្តិនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) រួមជាមួយ លោក ជាង សុខា ហិរញ្ញិកនៃសម្ព័ន្ធភាព និងជានាយកប្រតិបត្តិនៃកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) បានធ្វើដំណើរទៅទីក្រុងហ្សាកាតា ដើម្បីចូលរួមក្នុងសន្និសីទនេះ ។ សន្និសីទរបស់ EITI បាននាំយកនូវតំណាងរដ្ឋាភិបាលពាណិជ្ជករ និងមន្ត្រីសង្គមស៊ីវិលមកពីតំបន់អាស៊ី ដែលកំពុងពិចារណា ឬមានឆន្ទៈក្នុងការអនុវត្តតាមគោលការណ៍របស់ EITI ។

គួរជំរាបជូនថា EITI គឺជាបទដ្ឋានតម្លាភាពសកលសំរាប់ វិស័យឧស្សាហកម្មនិស្សារណកម្ម ដែលផ្តល់នូវយន្តការ ដែលត្រូវបានរាយការណ៍យ៉ាងសុក្រឹតទាំងការចំណាយរស់ក្រុមហ៊ុន ជូនទៅប្រទេសសាមី ព្រមទាំងផលចំណូលដែលរដ្ឋាភិបាលទទួលបានពីអាជីវកម្មប្រេងកាត ឧស្ម័ន ត្បូងថ្ម ធម្មជាតិ និងរ៉ែ ហើយរបាយការណ៍ទាំងនោះត្រូវបានបង្ហាញឱ្យអ្នកពាក់ព័ន្ធទាំងអស់បានដឹង និងចូលរួមក្នុងការពិភាក្សាតាមដានយ៉ាងទូលំទូលាយ ។

លោក ភីធ័រ អែហ្គិន (Peter Eigen) ប្រធាន EITI និងជាស្ថាបនិកអង្គការតម្លាភាពអន្តរជាតិបានមានប្រសាសន៍ថា "នេះជាសម្ព័ន្ធភាពរវាងរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល ដែលអាចប្រយុទ្ធប្រឆាំង នូវបណ្តាសាធនធានជាមួយជំនឿទុកចិត្ត និងជួយប្រែក្លាយធនធានធម្មជាតិទាំងនោះឱ្យក្លាយទៅជាពរជ័យសំរាប់សេចក្តីប្រាថ្នារបស់ពលរដ្ឋ" ។ គាត់បានបន្តថា "វាជាយុទ្ធសាស្ត្រត្រីកោណនៃអភិបាលកិច្ចល្អ ដែលអាចបង្កើតនូវបរិស្ថានសំរាប់អភិវឌ្ឍសង្គម និងសេដ្ឋកិច្ចពិតប្រាកដ" ។

## ប្រទេសអេក្វាទ័រៀលហ្គីណេ (Equatorial Guinea) បរាជ័យក្នុងការអនុវត្តតម្លាភាព ធ្វើឱ្យបាត់បង់បេក្ខភាពជាសមាជិករបស់គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម

ដោយ *Merrin Sterns* បុគ្គលិក ឌីភីអេ

ជាប្រទេសដែលមានប្រាក់ចំណូល ច្រើនជាងគេក្នុងទ្វីបអាហ្វ្រិក អេក្វាទូរៀលហ្គីណេ (Equatorial Guinea) ដែលស្ថិតនៅតាមឆ្នេរសមុទ្រតូចមួយនេះ គួរតែមានការរីកចំរើន ។ ជាមួយប្រេងកាតបំរុងទុកជាង ១កោដ បារ៉ែល និងឧស្ម័នធម្មជាតិយ៉ាងតិច ១៣០ពាន់កោដគូប ទ្រព្យសម្បត្តិទាំងអស់នេះគួរតែអាចអភិវឌ្ឍប្រទេស ដែលមានប្រជាជនសរុបច្រើនជាងកន្លះលាននាក់នេះ ឱ្យបានជឿនលឿន ដោយប្រើប្រាស់នូវប្រាក់ចំណូលដ៏ច្រើនសំបើមនេះ ដើម្បីចាប់ផ្តើមទាញយកផលចំណេញក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមិនលូតលាស់របស់ខ្លួន ឱ្យក្លាយជាផលប្រយោជន៍ដល់ប្រជាជន ។

វាគួរតែមានការអភិវឌ្ឍ ប៉ុន្តែរដ្ឋាភិបាលអេក្វាទូរៀលហ្គីណេ មិនទទម្លាប់ប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលមាន មកអភិវឌ្ឍវិស័យពាណិជ្ជកម្មឱ្យរីកចំរើនទៅមុខនោះទេ ។ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសបានកើនឡើងយ៉ាងគំហុកចាប់តាំងពីប្រាក់ចំណូលពីវិស័យប្រេង បានចាប់ផ្តើមគ្របដណ្តប់ទៅលើថវិកាជាតិនៅឆ្នាំ១៩៩៧ (អំឡុងពេលនៃការកើនឡើងដែលមិនធ្លាប់មាន) ប៉ុន្តែសូចនាករសេដ្ឋកិច្ចសង្គមក្នុងប្រទេសនេះ បង្ហាញថាបានធ្លាក់ចុះ ។

អត្រាអត់ការងារធ្វើបានឡើងដល់ ៣០% គួរឱ្យភ្ញាក់ផ្អើល ខណៈដែល ៦០% នៃប្រជាជនទាំងអស់ទទួលបានប្រាក់ចំណូលតិចជាង១ដុល្លាក្នុងមួយថ្ងៃ ។ ធៀបនឹងការចំណាយសរុបភាគរយនៃការចំណាយលើសេវាសង្គម ដូចជា ការថែទាំសុខភាព និងការអប់រំ បានធ្លាក់ចុះអស់កាលមួយទស្សវត្សមកហើយ ។ ចំណែក នៅលើតារាងសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សរបស់អង្គការសហប្រជាជាតិ បានចាត់ថ្នាក់ប្រទេសនេះ នៅបាតតារាងក្បែរប្រទេស ម៉ុលដូវ៉ា (Moldova) និងប្រទេសអ៊ុយបេគីស្ថាន (Uzbekistan) ។ លោក លីហ្វ វីន័រ (Leif Wenar) មន្ត្រីរបស់ក្រុមប្រឹក្សាភិបាលខាណេជី (The Carnegie) បានហៅប្រទេសអេក្វាទូរៀលហ្គីណេ ថាជា

តនៅទំព័រទី ៥

**មតិយោបល់ទាំងឡាយដែលបានលើកឡើងនៅទីនេះជាទស្សនៈរបស់អ្នកនិពន្ធសុទ្ធសាធ មិនមែនជាទស្សនៈរបស់ម្ចាស់ជំនួយឡើយ**

**ប្រតិទិននៃសកម្មភាពរបស់ ស៊ីអាអាធី**

**ថ្ងៃទី០៤-០៥ ខែសីហា ឆ្នាំ២០១០**

**អ្វី** : វគ្គបណ្តុះបណ្តាលយុវជនស្តីពី "វិស័យឧស្សាហកម្មនិស្សារណកម្ម"

**នៅកន្លែងណា** : **វ៉ាយអរឌីភី នៅភ្នំពេញ**

**នៅម៉ោងប៉ុន្មាន** : ចាប់ផ្តើមពីម៉ោង ៧ព្រឹក ដល់ម៉ោង ៥ល្ងាច

**ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០**

**អ្វី** : វេទិកាយុវជនស្តីពី "វិស័យឧស្សាហកម្មនិស្សារណកម្ម"

**នៅកន្លែងណា** : **ខេត្ត កំពង់សោម**

**នៅម៉ោងប៉ុន្មាន** : ចាប់ផ្តើមពីម៉ោង ៧ព្រឹក ដល់ម៉ោង ៥ល្ងាច

**ស៊ីអាអាធី**

សូមទំនាក់ទំនង កញ្ញា ហៀង ជាមន្ត្រីទំនាក់ទំនងរបស់ ស៊ីអាអាធី

**ទូរស័ព្ទលេខ** : ៨៥៥-១២-៥០០-៩២២

**លេខការិយាល័យ** : ៨៥៥-២៣-២១៧-៦០៧

**អ៊ីម៉ែល** : crrtcommunications@online.com.kh

**គេហទំព័រ** : www.crrt-cambodia.org.kh

**អាស័យដ្ឋានរបស់ ស៊ីអាអាធី**

បន្ទប់ ៤៨៥ អាគារ F មជ្ឈមណ្ឌលភ្នំពេញ កែងផ្លូវ ២៧៤ និង៣ រាជធានី ភ្នំពេញ ប្រទេសកម្ពុជា

Danida HEINRICH BÖLL STIFTUNG CAMBODIA MISEREOR DAS HILFSWERK Oxfam TRÓCAIRE Working for a Just World

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

# CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

Issue N⁰ 04

June 2010



*Photo: AP, This big pelican is soaked with spill oil in Gulf of Mexico.*

## Firm Date Set for Oil Flow

*By Vong Sokheng, Phnom Penh Post*

*02 July 2010*

THE long-awaited production of oil in Cambodia is scheduled to commence in December 2012, a leading government official said yesterday, following positive results from off-shore drills.

Deputy Prime Minister Sok An, chairman of the Cambodian National Petroleum Authority, is reported to have set a production date at a speech made to Puthisatra University students at Raffles Le Royal Hotel in Phnom Penh yesterday.

"We hope have the first drop of oil produced on December 12, 2012, at 12am," he said in a statement, later confirmed by spokesman at the Council of Ministers Phay Siphan.

A source told the Post that the com-

**Continued on page 2**

## CRRT Host President of Timor-Leste and Nobel Peace Prize Laureate, Dr. José Ramos-Horta

*By John Forrest Millock, CRRT Staff*

On April 23, 2010, Cambodians for Resource Revenue Transparency, International Peace Foundation, and the Heinrich Böll Foundation jointly hosted the roundtable discussion,"Transforming Natural Resource Wealth into a Source for Sustainable Growth and Democratic Development." The roundtable brought two guest speakers: H.E. Dr. José Ramos-Horta, a 1996 Nobel Peace Prize Laureate and current President of Timor-Leste, as well as Dr. Phan Phalla, the Deputy Secretary General of the Supreme Economic Council of Cambodia. The keynote speakers examined several topics, including: extractive industries in Cambodia and national methods of resource management; examples of sustainable re-

**Continued on page 2**

### VISION:

The vision of CRRT is that wealth generated from extractive industries is managed in a socially responsible manner that is transparent, accountable, and participatory to equitably benefit all Cambodians.

## Gulf Spill a Reminder of Cambodia Shortfalls

*By Pich Samnang, VOA Khmer, Phnom Penh*

*08 June 2010*

The BP oil spill, now in its sixth week, has poured thousands of barrels of oil into the sea. The environmental costs are likely to be huge, but the political costs are now beginning to mount for the US administration.

Analysts in Cambodia say that if the country does not want to undergo a similar experience, the government must put in place certain protective mechanisms.

Cambodia lacks a coast guard authority, a safety administration and protective agreements with companies who are exploring Cambodia's oil and gas reserves, even though it expects oil to start flowing by 2012.

**Continued on page 3**

### CONTENTS

- Firm Date (Cont.) ...........2
- CRRT Host (Cont.) ...........2
- Gulf Spill (Cont.) ...........3
- Transparency Increases .......4
- Equatorial Guinea ............5
- EITI Seminar ............6

Continued from page 1

## Firm Date Set...

ment came after a high-level CNPA meeting with firms with interests in offshore Block A – a 4,709-square-kilometre area of the Gulf of Thailand.

Interests in Block A are held by energy giant Chevron, which operates the concession and has a 30 percent stake, Japanese Mitsu Oil Exploration Cooperation (Moeco), which also holds 30 percent, Kris Energy with 25 percent, and South Korea's GS Caltex with 15 percent.

In April, Prime Minister Hun Sen ordered Chevron to start production by 2012 or forfeit its licence.

According to the source, four shareholders from the companies took part in a review with the CNPA on Friday in which positive results from three drill wells in the block were reported.

The companies are expected to submit a final production report on September 18, the deadline for the renewal of their exploration licence, the source said.

He added that the shareholders have expressed concern over apparent disparities between a taxation law and the draft Petroleum Law – which they hope is a "priority" for National Assembly approval.

Chevron spokesman Gareth Johnstone did not respond to an emailed request for a detailed update on extraction progress in Block A and did not confirm a production date had been set yesterday.

However, he did state in an email that: "We are aligned with the Royal Government of Cambodia desire to see production from Block A as soon as economically possible.

"The first oil date is reliant on a successful exploration program, and is dependent on achieving key milestones."

Te Doung Tara, head of CNPA, could not be reached for comment yesterday.

In a letter dated June 9, Sok An confirmed to the Sam Rainsy Party that 23 companies have been awarded rights to explore for oil in Cambodia, although not all of them are still operating.

He also confirmed that Total had paid US$28 million for a concession, $20 million of which was a signature bonus, with $6 million to be paid into a social-development fund, and another $2 million earmarked for administrative purposes.

***This article has been reprinted with the permission of the Phnom Penh Post.***

Continued from page 1

## CRRT Host...

source management practices (looking specifically at Timor-Leste as a case study), and the significance of transparency in the extractives industries.

President Ramos-Horta spoke about his country's development of natural resources, saying, "With support from the United Nations and development partners our government is engaging people throughout the country." He explained various measures that the government of Timor-Leste has been taking to improve transparency, prevent corruption, and engage with communities, such as establishing checks and balances by putting the revenues of oil and gas through a budget process and not giving the government direct access to the revenues.

As a member of the Extractive Industries Transparency Initiative (EITI), Timor-Leste has passed a petroleum law to govern the management of its oil and gas resources and established a Petroleum Fund and Petroleum Fund Management Department charged with the responsible investment of petroleum revenue and accountable to the central bank. In addition to this, whenever the country wants to develop a strategy and plan for the nation, public consultation is required. President Ramos-Horta stated, "I offer you a better return for your investment than Mr. Bernard Madoff promised, you know Bernard Madoff, the New York Banker, now in jail, who offered return of 8% or 10%. I offer a 100% return, if we invest more in education from elementary school to university, if we invest more in health, in agriculture, in road, and more roads. I guarantee you in 20 years; you will have a 100% return."

When discussing the issue of government corruption, President Ramos-Horta admitted that Timor-Leste was still struggling with corruption, but stressed that the Minister and the Directors of any department that had corruption had a responsibility to stop it. Dr. Phan Phalla compared Cambodia's experience with natural resources to Timor Leste's, highlighting the infancy of Cambodia's mining and oil/gas industry, as well as its governing structure. Dr. Phalla also highlighted what he perceives to be a major hurdle Cambodia must overcome in order to grow its mining, oil and gas industries: capacity limitations in terms of a shortage of engineers and infrastructure.

Over 200 participants attended the event, from government officials, university students, civil society organizations, local non-government organizations, international non-government organizations, donors, the private sector, and university students. Timor-Leste is widely recognized for the successful management of its oil and gas revenues, upon which approximately 80% of its economy relies without operating in mining.

Continued from page 1

# Gulf Spill a Reminder...







"In response to any possible oil spill in the future, a coast guard authority and a petroleum safety administration should be set up to be in charge of safeguarding the environment," Mam Sambath, chairman of the Cambodians for Resource Revenue Transparency, a coalition of non-governmental agencies, said. "All of the companies exploring for oil should also be encouraged to create an association which is tasked with coping with the possible oil spill."

The newly established authorities should not be put under the existing Cambodian National Petroleum Authority so that separated technical management can be ensured for an effective mechanism, Mam Sambath said.

At least 13 companies have so far been granted exploration licenses with some already beginning exploration. Full drilling could begin soon in what experts estimate is a reserve of 400 million to 700 million barrels of oil worth billions of dollars. However, the money comes with risks, as the Gulf spill has shown, and observers say Cambodia lacks the institutions and agreements to deal with them.

Ou Virak, president of Cambodian Human Rights Center, who also manages a website monitoring development trends, said the government also needs to make a protective agreement with oil companies to have all the necessary precautious put in place.

"Any company granted the extracting right has to be tasked with setting up detailed plans to protect the environment and the people, who might be affected by a possible oil incident," he said. "If any company does not provide the protective plans or if the plans are not reasonable or inadequate, the government should reject them."

The government could also apply for an Extractive Industries Transparency Initiative to learn from other member countries ways to better manage oil risks, as well as revenues. EITI works with more than 30 countries to increase transparency and accountability in oil revenue.

Government spokesman Khieu Kanharith said EITI candidate status for Cambodia is not necessary because the country is already transparent in managing its oil revenue. The establishment of additional authorities to deal with any possible oil spill is not needed either, he said, as the country already has the National Petroleum Authority.

"If we created some more authorities, we would be criticized for spending more money," he said.

National Petroleum Authority officials declined to comment on protective mechanisms for possible oil spills.

However, Cheam Yiep, a ruling party National Assembly member, said the Gulf spill had encouraged lawmakers to push for separate agreements with oil companies to ensure Cambodia is better prepared for such an incident.

"We will use the US experience as an example and basis for discussion and for an agreement with companies to extract oil in our country," he told VOA Khmer.

Yim Sovann, an opposition lawmaker, said parliament needs to enact more laws to guarantee safety in the oil industry and that it needs to push the government to apply for EITI status to ensure transparency and accountability in management of revenue from the extractive industries.

***This article has been reprinted with the permission of VOA Khmer.***

# Transparency Increases, But There is Still a Long Way to Go

*By Steve Finch, Phnom Penh Post, 14 May 2010*

DURING an otherwise routine presentation on the Cambodian economy on March 17, Ministry of Economy and Finance Director General Hang Chuon Naron chose the very last slide to offer a rare, detailed glimpse of Cambodia's expanding oil and gas revenues.

The decision has since proven to be both a milestone in Cambodian transparency, and a millstone around the government's neck.

On one hand, Hang Chuon Naron's disclosure that the government received US$800,000 in December and $26 million in January for energy "signature bonuses" and a "social fund" represented a new level of state transparency for extractive industry payments in the Kingdom.

Subsequently, however, Prime Minister Hun Sen's government has faced increasingly difficult questions on where the money came from, how it is being spent and to what degree payments derived from the extractives industry will be opened up for public scrutiny.

The missing $500,000 reportedly paid to the government by the world's largest iron ore producer BHP Billiton – now the subject of a US securities and exchange commission enquiry – looks to be just the start of a period in which the government has increasingly been asked the question: Where has all this money gone?

For the first time, the Cambodian government has published state revenues publicly that detail payments foreign energy and mining companies have made to operate in the Kingdom. A TOFE (state financial operations notice) partly issued on the Finance Ministry website and fully presented at last month's Oxfam America extractive industries conference in the capital showed the state received some 9.323 billion riels, or $2.25 million, from the sector in 2009. Of this total, 6.003 billion riels ($1.45 million) came from mining companies, with the remaining $800,000 derived from the oil and gas sector, according to official government figures.

But with Australian mining companies OZ Minerals and Southern Gold looking at imminent gold production in Cambodia, and US energy firm Chevron under pressure from the government to begin oil production as soon as 2012, the political opposition, civil society and the UN – among others – are pushing the government to go further on what they say is still limited disclosure.

"I think [this is] the first step, the first step that the government has [made] … to disclose this information to the public," said Mam Sambath, chairman and executive director of the NGO Cambodians for Resource Revenue Transparency (CRRT).

**For the first time, the Cambodian government has published state revenues publicly that detail payments foreign energy and mining companies have made to operate in the Kingdom.**

"But they should improve how to disclose information by having more detailed information," he added.

### Seeking Full Disclosure

COMPLIANCE with the Extractive Industries Transparency Initiative requires a high level of disclosure and numerous steps that begins with a government commitment and ends with an external validation process. To sign up as an EITI candidate country, achieved by 29 nations thus far, a government must commit to working with stakeholders – including the private sector and civil society – before appointing an implementation leader and then publishing fully costed work plan. Once a candidate, the first step is then to establish a multi-stakeholder working group.

In this regard, Cambodia has again shown some willingness although NGOs have only been permitted to be observers in discussions on financial reform. Importantly, the government – led by the Ministry of Economy and Finance – has blocked a request for civil society to become a full partner of the financial reform process that began at the beginning of last year. Were Cambodia to reach this stage of the EITI process, the government would have to allow full access. Another major step would be to engage companies, something the government has shown a greater tolerance for in the past by allowing the likes of Chevron to help draw up petroleum legislation. Under the EITI, preparation phase, the government would then be required to agree reporting templates and an independent EITI administrator while ensuring state and company accounts are properly audited.




The next stage–disclosure–then requires full openness with an administrator on private sector payments as part of a process in which these two sets of accounts would be reconciled to account for differences. This is the key area in which Cambodia is currently

Continued on next page

# Equatorial Guinea Fails to Embrace Transparency, Loses EITI Candidate Status

*By Merrin Sterns, DPA staff*

As Africa's most prosperous country by per capita income , the tiny coastal nation of Equatorial Guinea should, by all measures, be thriving. With petroleum reserves of over 1 billion barrels and natural gas deposits totaling at least 1.3 trillion cubic feet, this pocket-sized country of just over half a million inhabitants should be developing rapidly, using the huge profits that these natural resources generate to kick start its once-trifling economy for the benefit of its long-suffering citizens.

But "should" is not a currency in which the Equatoguinean government is accustomed to trade. The country's GDP has increased exponentially since enormous oil profits began to inundate state coffers in 1997, but even in this period of unprecedented boom, many socioeconomic indicators in the country have actually decreased. Unemployment hovers at an astonishing 30% , while 60% of the population subsists on less than $1 a day . Spending on social services such as health care and education has declined as a percentage of total spending over the last decade, and the country remains firmly entrenched at the bottom end of the UNDP's Human Development Index, alongside Moldova and Uzbekistan . The Carnegie Council's Leif Wenar calls Equatorial Guinea a "pure case of a country currently stricken by the resource curse" while another report contends that Equatorial Guinea presents "perhaps the most striking example of why oil hurts, rather than helps, many of the countries who have it."

In this context of corruption and mismanagement, a flicker of hope emerged in the form the Extractive Industries Transparency Initiative (EITI), a voluntary regulation system to which Equatorial Guinea made initial moves to accede in 2007. Achieving EITI Compliant Status would have afforded Equatoguineans a guarantee of transparency in resource revenue management by obligating the government to not only publish figures of contracts and payments, but also allow civil society to operate freely and openly, even when addressing sensitive topics.

Alas, that flicker of hope was extinguished this April, when EITI Board members met in Berlin and voted to deny Equatorial Guinea's request for an extension of a key deadline, terminating the country's candidacy. While the EITI Board stressed the possibility of reapplication once "barriers to effective implementation have been addressed," it also noted that "a country cannot claim EITI candidate status while performing well short of the requirements". Watchdog groups agree that Equatorial Guinea showed little sign of reversing the opaqueness which has characterized its handling of oil monies thus far, and few were surprised by the EITI Board's decision.

In the absence of a regulatory framework which demands transparency and openness, it unlikely that Equatorial Guinea will adopt these principles on its own. Continuing on its current course, then, the country appears ever more condemned to live out the resource curse, squandering the promise of a brighter future in favor of a quick dollar for those at the top.

Continued from page 4

# Transparency Increases...

well short of the required standard in that neither the state or private sector is disclosing payments fully, in accordance with binding, negotiated contracts that bar the release of related data. Once a country completes such a report it is then required to publish it. An examination of companies' implementation support is then followed by a review. Following external evaluation, the country would then become EITI compliant.

**EITI Compliant Countries:**

Azerbaijan and Liberia

**EITI Candidate Countries:**

Afghanistan, Albania, Burkina Faso, Cameroon, Central African Republic, Chad, DR Congo, Republic of Congo, Ivory Coast, Gabon, Ghana, Guinea, Iraq, Kazakhstan, Mali, Mauritania, Madagascar, Mongolia, Mozambique, Niger, Nigeria, Norway, Peru, Sierra, Leone, Tanzania, Timor-Leste, Yemen and Zambia.



*Sok An signs an exploration agreement with Japan's JOGMEC on May 4 in Phnom Penh.*

*Photo: Pha Lina*

***This article has been excerpted and reprinted with the permission of the Phnom Penh Post.***

**To Be Continued in Issue 5**

# EITI Seminar in Jakarta

*By Kim Philley, CRRT Staff*

CRRT members were invited by EITI, World Bank, the Federal Ministry for Economic Cooperation and Development, and InWent, to attend a seminar on the unique opportunities and challenges of implementing EITI in Asia, held from March 1-4, 2010, in Jakarta, Indonesia.



**Photo: CRRT member, Round table discussion with members of the CRRT coalition, EITI seminar in Jakarta**

Mr. Cheang Sokha, Treasurer of CRRT and Executive Director of YRDP, and Mr. Chhith Sam Ath, Vice Chairman of CRRT and Executive Director of NGO Forum, traveled to Jakarta to attend this conference. The EITI seminar brought together representatives of government, business, and civil society from Asian countries that are considering, or have already committed to, implementing EITI.

EITI is a global transparency standard for the extractive industries that provides a mechanism whereby both company payments to host governments and government revenues generated from petroleum, coal, natural gas, and mineral extraction are fully reported—disclosed and reconciled under the supervision of all stakeholders in a country.

Peter Eigen, the global Chairman of EITI and founder of Transparency International, said, "It is the coalition between governments, the private sector, and an organized civil society that can fight the resource curse with credibility and passion and help turn natural resources into a blessing for the people. It is this 'magic triangle' of good governance that can create the environment for real social and economic development."

**The opinions expressed herein are those of the authors and do not necessarily reflect the views of all donors.**

**CRRT Activities Calendar**

4-5 August 2010

What : Youth Training on Extractive Industry

Where : YRDP, Phnom Penh

When : 7:30 a.m. - 5:00 p.m.

20 August 2010

What : Youth Forum on Extractive Industry

Where : Kompong Som Province

When : 7:30 a.m. - 5:00 p.m.

**Cambodians for Resource Revenue Transparency (CRRT)**

Contact : Ms. Thy Heang, CRRT's Communications Officer

Mobile Phone : 855-12-500-922

Office Phone : 855-23-217-607

E-mail : com@crrt-cambodia.org

Website : www.crrt-cambodia.org

**Address:** Suite 485, Building F, Phnom Penh Center, Corner Street 274/3, Phnom Penh, Cambodia

Danida | HEINRICH BÖLL STIFTUNG CAMBODIA | MISEREOR DAS HILFSWERK | NORWEGIAN PEOPLE'S AID | Oxfam | TRÓCAIRE Working for a Just World